# អនុសញ្ញាអន្តរជាតិស្តីពីការលុប
# បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍



ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# អនុសញ្ញាអន្តរជាតិ

# ស្តីពី

# ការបំបាត់រាល់ទម្រង់ នៃ

# ការរើសអើងពូជសាសន៍

ខែកញ្ញា ឆ្នាំ២០០៩

រូបភាពក្រុមដោយ  ការិយាល័យ  OHCHR នៅកម្ពុជា

នេះគឺជាការបោះពុម្ពផ្សាយដោយការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា

អង្គការសហប្រជាជាតិ
សិទ្ធិមនុស្ស
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស
ការិយាល័យប្រចាំកម្ពុជា . ភ្នំពេញ

# អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍

## សេចក្តីផ្តើម

អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិកាលពីថ្ងៃទី២១-ធ្នូ-១៩៦៥។ សន្ធិសញ្ញានេះបានចូលជាធរមានតាមច្បាប់អន្តរជាតិនៅថ្ងៃទី៤-មករា-១៩៦៩។ អនុសញ្ញានេះ គឺជាសន្ធិសញ្ញាដែលចាស់ជាងគេ ក្នុងចំណោមសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់៧ទាំងអស់ ហើយ១ឆ្នាំបន្ទាប់មកទៀត ទើបមានកតិកាសញ្ញាសំខាន់ពីរទៀត ត្រូវបានអនុម័ត គឺកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ និងកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌។

រាល់សន្ធិសញ្ញាសិទ្ធិមនុស្សមានប្បញ្ញត្តិហាមឃាត់ពីការរើសអើង រួមទាំងការរើសអើងដោយឈរលើមូលដ្ឋាន ពូជសាសន៍ និងដើមកំណើតជនជាតិ។ ដូច្នេះ មាត្រា២ នៃកតិកាសញ្ញាទាំងពីរ គឺកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងកតិកាសញ្ញាស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចែងថា បុគ្គលទាំងអស់ មានសិទ្ធិទទួលបានសិទ្ធិមនុស្ស "ដោយគ្មានការបែងចែកនៃប្រភេទណាមួយឡើយ ដូចជាជាតិសាសន៍ ពណ៌សំបុរ ភេទ ភាសា សាសនា គំនិតនយោបាយ ឬគំនិតផ្សេងទៀត ដើមកំណើតជាតិ ឬសង្គម ទ្រព្យសម្បត្តិ ដើមកំណើត ឬឋានៈផ្សេងទៀត។" អនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការ

រើសអើងពូជសាសន៍គឺពង្រឹងពីប្បញ្ញត្តិហាមឃាត់នេះ។ អនុសញ្ញានេះមានចែង ពីគោលការណ៍ណែនាំបន្ថែមទៀត ដល់រដ្ឋភាគី ពីវិធានការនានាដែលគួរធ្វើ ដើម្បីប្រយុទ្ធប្រឆាំងនឹងការរើសអើងពូជសាសន៍។ អនុសញ្ញានេះ បានកកើត ឡើងពីការឆ្លើយតបរបស់សហគមន៍អន្តរជាតិចំពោះរបបអាប៉ាថេតនៅអាហ្រ្វិចខាងត្បូង ទីដែលជនភាគតិចស្បែកសបានប៉ុនប៉ងដាក់ការគ្រប់គ្រងរបស់ខ្លួន លើជនភាគច្រើនស្បែកខ្មៅនៅក្នុងប្រទេស បណ្តាលឱ្យមានការរំលោភសិទ្ធិមនុស្សយ៉ាងច្រើន។

## តើអនុសញ្ញាមានចែងពីអ្វីខ្លះ ?

អនុសញ្ញាចែងថា រដ្ឋភាគីគួរតែទប់ស្កាត់នូវការរើសអើង ដោយឈរលើមូលដ្ឋានពូជសាសន៍ គួរតែចាត់វិធានការសមស្រប លប់បំបាត់នូវការរើសអើងពូជសាសន៍ និងឥរិយាបទរើសអើងពូជសាសន៍ និងចែងថាសិទ្ធិមនុស្សទាំងអស់ គួរត្រូវបានធានាការពារនៅក្នុងប្រទេសនីមួយៗ ដោយគ្មានការបែងចែកដោយសារតែពូជសាសន៍នោះទេ។ អនុសញ្ញាចែងផងដែរថា ជនរងគ្រោះនៃការរើសអើងពូជសាសន៍គួរតែមានដំណោះស្រាយដ៏មានប្រសិទ្ធភាពមួយ ទោះតាមរយៈតុលាការ ឬតាមស្ថាប័ន ឬយន្តការដទៃខ្លះទៀត។

មាត្រា៥ នៃអនុសញ្ញាមានរាយបញ្ជីមួយចំនួន នៃសិទ្ធិមនុស្សជាក់លាក់ទាំងសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ចនិងវប្បធម៌ និងសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលរដ្ឋភាគី ត្រូវធានាការពារ ដល់ជនគ្រប់រូប ដោយមិនគិតពី ពូជសាសន៍ពណ៌សំបុរ ឬដើមកំណើតជនជាតិ។ បញ្ជីនៃសិទ្ធិទាំងនេះមិនទាន់អស់ត្រឹម

នេះទេ ការហាមឃាត់ពីការរើសអើងពូជសាសន៍អនុវត្តចំពោះសិទ្ធិមនុស្សទាំងអស់ដែលនៅជាធរមាននៅក្នុងប្រទេស។ មូលហេតុដែលមាត្រា៥រាយបញ្ជីពីសិទ្ធិសំខាន់ៗខ្លះនោះ គឺដោយសារកតិកាសញ្ញាអន្តរជាតិចំនួនពីរ អធិប្បាយពីវិសាលភាពទាំងស្រុង នៃសិទ្ធិមនុស្ស ដែលមានចែងក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនោះមិនទាន់ត្រូវបានរៀបរៀងចប់នៅឡើយ នៅពេលដែលអនុសញ្ញានេះត្រូវបានអនុម័ត។

ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការើសអើងពូជសាសន៍ នៅឆ្នាំ១៩៨៣។ តាមរយៈការចូលជាសមាជិកនេះ ព្រះរាជាណាចក្រកម្ពុជា បានប្តេជ្ញាខ្លួន ធានាការលុបបំបាត់ការរើសអើងពូជសាសន៍ តាមគ្រប់ទម្រង់ទាំងអស់ពីកម្ពុជា។

## តើការរើសអើងពូជសាសន៍ជាអ្វី ?

អនុសញ្ញាឱ្យនិយមន័យយ៉ាងទូលំទូលាយពីការរើសអើងពូជសាសន៍ដោយរួមបញ្ចូល ការបែងចែកណាមួយ ការផាត់ចេញណាមួយ ការដាក់កំហិតណាមួយ ឬការចូលចិត្តណាមួយ ដោយឈរលើមូលដ្ឋានពូជសាសន៍ ពណ៌សំបុរដើមកំណើត ឬដើមកំណើតជាតិ ឬជនជាតិ ដែលមានបំណង ឬមានអានុភាពបដិសេធ ឬធ្វើឱ្យខូចខាតដល់ការទទួលស្គាល់ ការទទួលបាន ឬការអនុវត្តន៍សិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន នៅក្នុងវិស័យនយោបាយ សេដ្ឋកិច្ចសង្គមកិច្ច វប្បធម៌ និងវិស័យដទៃទៀតនៃជីវភាពសាធារណៈ ដោយឈរលើគោលការណ៍ស្មើភាពគ្នា” (មាត្រា១)។

តាមរយៈនិយមន័យនេះ ការរើសអើងពូជសាសន៍ បង្វិលជុំវិញការរើសអើងប្រឆាំងនឹងនិគមជនភាគតិច ប្រជាជនដើមភាគតិច និងប្រជាជននៃជាតិដទៃទៀត ហើយនិយមន័យនេះក៏បានរួមបញ្ចូលទាំងវណ្ណៈសង្គម ជនភាគតិចខាងសាសនា និងខាងភាសាផង។

នៅក្នុងបរិបទកម្ពុជា នេះមានន័យថា រដ្ឋាភិបាលត្រូវធានាថា ក្រុមជនភាគតិចទាំងអស់នៅកម្ពុជា ត្រូវតែអាចទទួលបានសិទ្ធិមនុស្ស ដោយឈរលើមូលដ្ឋានដូចគ្នាដូចប្រជាជនភាគតិចខ្មែរដែរ។ ក្រុមជនភាគតិចទាំងនេះរួមមាន:

- ប្រជាជនដើមភាគតិចនៃកម្ពុជា ជួនកាលសំដៅលើខ្មែរលើ
- ខ្មែរក្រោម (គឺជាប្រជាជនខ្មែរដែលមានដើមកំណើតនៅប្រទេសវៀតណាមខាងត្បូងសព្វថ្ងៃ)
- សហគមន៍វៀតណាម និងចិននៅកម្ពុជាមិនគិតថាគេបានកើតនៅកម្ពុជា ឬជាជនអន្តោប្រវេសន្តន៍
- សហគមន៍ជនជាតិចាមមូស្លីមដែលជួនកាលសំដៅលើជនជាតិខ្មែរឥស្លាម
- សហគមន៍ជនជាតិអាហ្វ្រិចនៅភ្នំពេញ
- ជនជាតិផ្សេងទៀតដែលមិនមែនជាជនកម្ពុជារស់នៅកម្ពុជា

## តើអនុសញ្ញាអនុវត្តយ៉ាងដូចម្តេចនៅកម្ពុជា ?

ព្រះរាជាណាចក្រកម្ពុជា បានក្លាយជារដ្ឋភាគីនៃអនុសញ្ញាអន្តរជាតិ ស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍នៅថ្ងៃទី២៨-ធ្នូ-១៩៨៣ មាត្រា៣១នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ធានាការពារអនុសញ្ញានេះ និងសន្ធិសញ្ញា

សិទ្ធិមនុស្សអន្តរជាតិដទៃទៀត ថាជាផ្នែកមួយនៃច្បាប់ជាតិកម្ពុជា។ លើសពីនេះទៅទៀត មាត្រា៣១ ចែងថា ប្រជាពលរដ្ឋខ្មែរទាំងអស់ មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។ តាមរយៈបទប្បញ្ញត្តិនេះ គោលការណ៍នៃការមិនរើសអើង ត្រូវបានតំកល់ទុកក្នុងច្បាប់ធម្មនុញ្ញកម្ពុជា។

នៅក្នុងសេចក្តីរបស់ខ្លួន កាលពីថ្ងៃទី១០-កក្កដា-២០០៧ ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នមួយបង្កើតឡើងដើម្បីការពាររដ្ឋធម្មនុញ្ញ បានគូសបញ្ជាក់ជាថ្មី ពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិនៅក្នុងច្បាប់ជាតិកម្ពុជា និងធ្វើការរំលឹកដល់ចៅក្រមក្នុងការកាត់ក្តី និងក្នុងការបកស្រាយច្បាប់ថា ចៅក្រមត្រូវតែប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវបទប្បញ្ញត្តិសន្ធិសញ្ញារួមទាំងអនុសញ្ញាអន្តរជាតិស្តីពីការលប់បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ផងដែរ។ នេះមានន័យជាក់ស្តែងថា តុលាការនៅកម្ពុជា ជានិច្ចកាល ត្រូវបកស្រាយច្បាប់កម្ពុជា ដោយមិនមានការរើសអើង ដោយសារពូជសាសន៍នោះឡើយ។

## គណៈកម្មាធិការលប់បំបាត់ការរើសអើងពូជសាសន៍

ដោយបានក្លាយខ្លួនជារដ្ឋភាគីនៃអនុសញ្ញា រដ្ឋនោះត្រូវធ្វើការប្តេជ្ញាចិត្តដោយភ្ជាប់កាតព្វកិច្ចផ្លូវច្បាប់ចំពោះប្រជាពលរដ្ឋរបស់ខ្លួន ព្រមទាំងសហគមន៍

អន្តរជាតិ ក្នុងការអនុវត្តបទបញ្ញត្តទាំងឡាយនៃអនុសញ្ញានេះ ដើម្បីលើកស្ទួយ និងការពារសិទ្ធិបុគ្គលរាល់រូប ដោយគ្មានការរើសអើងពូជសាសន៍ នៅក្នុងប្រទេស។

យោងតាមអនុសញ្ញានេះ គណៈកម្មាធិការអន្តរជាតិមួយ ដែលមានអ្នកជំនាញការឯករាជ្យ ហើយដែលគេស្គាល់ជាទូទៅថា គណៈកម្មាធិការលប់បំបាត់ការរើសអើងពូជសាសន៍ ត្រូវបានបង្កើតឡើង ដើម្បីតាមដានការវិវត្តន៍របស់រដ្ឋភាគី ក្នុងការបំពេញតាមការប្តេជ្ញាចិត្តរបស់ខ្លួន។ គ្រប់រដ្ឋភាគីតំរូវឱ្យធ្វើរបាយការណ៍ជាទៀងទាត់តាមកាលកំណត់ជូនគណៈកម្មាធិការ ពីវិធានការដែលខ្លួនប្រកាន់យក ដើម្បីអនុវត្តអនុសញ្ញានេះ។ របាយការណ៍នេះ ត្រូវធ្វើជាទៀងទាត់ទៀងរាល់ពីរឆ្នាំម្តង ទោះបីរដ្ឋជាច្រើនមានធ្វើរបាយការណ៍តាមអនុសញ្ញាទៀងរាល់បួនឆ្នាំម្តងតាមសន្ធិសញ្ញាសិទ្ធិមនុស្សដទៃទៀតក៏ដោយ។

កម្ពុជា បានធ្វើរបាយការណ៍ចំនួនពីរលើករួចមកហើយ ជូនគណៈកម្មាធិការ គឺកាលពីឆ្នាំ១៩៨៥ និងឆ្នាំ១៩៩៨។ រដ្ឋាភិបាលបានដាក់របាយការណ៍តាមកាលកំណត់លើកទី៨ ដល់លើកទី១៣បញ្ចូលគ្នា តែមួយរបាយការណ៍ កាលពីខែកុម្ភៈ ឆ្នាំ២០០៩ ហើយគណៈកម្មាធិការនឹងពិនិត្យរបាយការណ៍នេះ នៅក្នុងសម័យប្រជុំរបស់ខ្លួន នៅទីក្រុងហ្សឺណែវ នៅខែកុម្ភៈ ឆ្នាំ២០១០។

មាត្រា១៤ នៃអនុសញ្ញា អនុញ្ញាតឱ្យរដ្ឋភាគី ធ្វើការជ្រើសរើស ក្នុងការអនុញ្ញាតឱ្យគណៈកម្មាធិការ ទទួល និងពិចារណាបណ្តឹងពីឯកត្តបុគ្គល ឬក្រុមក្នុងប្រទេសរបស់ខ្លួន ដែលប្តឹងទាមទារថា សិទ្ធិរបស់ពួកគេ តាមអនុសញ្ញាត្រូវបានបំពាន។ សន្ធិសញ្ញាដទៃខ្លះទៀត មានបទប្បបញ្ញត្តប្រហាក់ប្រហែល

គ្នា ដែលដាក់បញ្ចូលទៅក្នុងពិធិសារបន្ថែម តែតាមពិត ប្រសិទ្ធភាពគឺដូចគ្នា។ ដើម្បីធ្វើឱ្យមាត្រា១៤មានអានុភាពលើរដ្ឋមួយ រដ្ឋនោះ ត្រូវធ្វើសេចក្តីប្រកាសមួយ ទៅអង្គការសហប្រជាជាតិ ដោយថ្លែងថា ខ្លួនអនុញ្ញាតឱ្យមានបណ្តឹងជាឯកត្តបុគ្គលពីរដ្ឋរបស់ខ្លួន។ រហូតមកដល់សព្វថ្ងៃនេះ កម្ពុជាមិនទាន់បានធ្វើសេចក្តីប្រកាសបែបនេះនៅឡើយទេ ហេតុដូច្នេះហើយ គណៈកម្មាធិការ មិនអាចពិនិត្យបណ្តឹងឯកត្តបុគ្គល ពីកម្ពុជាបានទេ។

ការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិ
ទទួលបន្ទុកសិទ្ធិមនុស្ស-ការិយាល័យប្រចាំនៅកម្ពុជា
ខែសីហា ឆ្នាំ២០០៩

# អនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងពូជសាសន៍

ត្រូវបានអនុម័ត និងបើកឱ្យចុះហត្ថលេខា និងឱ្យសច្ចាប័នតាមសេចក្តីសម្រេចលេខ ២១០៦A (XX)
ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៦៥ របស់មហាសន្និបាតអង្គការសហប្រជាជាតិ
ចូលជាធរមាននៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៦៩ ស្របតាមបទបញ្ញត្តិនៃមាត្រា១៩

***រដ្ឋភាគីនៃអនុសញ្ញានេះ***

*យល់ឃើញថា* ធម្មនុញ្ញសហប្រជាជាតិ ផ្អែកលើគោលការណ៍នៃសេចក្តីថ្លៃថ្នូរ និងសមភាពដែលជាប់ពីកំណើតមនុស្សគ្រប់រូប *និងថា* រដ្ឋភាគីទាំងអស់បានសន្យាចាត់វិធានការរួមគ្នា និងដោយឡែកពីគ្នា ដោយសហប្រតិបត្តិការជាមួយ អង្គការសហប្រជាជាតិ ដើម្បីសម្រេចទិសដៅមួយរបស់សហប្រជាជាតិក្នុងការលើកស្ទួយនិងជំរុញឱ្យមានការគោរព និងការអនុវត្តន៍ជាសកលនូវសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋានសម្រាប់ទាំងអស់គ្នា ដោយគ្មានការប្រកាន់បែងចែក មានជាអាទិ៍ ពូជសាសន៍ ភេទ ភាសា ឬសាសនា ។

*យល់ឃើញថា* សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ប្រកាសថា មនុស្សគ្រប់រូប កើតមកមានសេរីភាព និងស្មើភាពខាងសេចក្តីថ្លៃថ្នូរ និងសិទ្ធិ និងថា ជនគ្រប់រូបមានសិទ្ធិ និងសេរីភាពទាំងអស់ដែលមានចែងក្នុងសេចក្តីប្រកាស ដោយគ្មានការប្រកាន់បែងចែកណាមួយ ពិសេសខាងពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ។

*យល់ឃើញថា* មនុស្សជាតិគ្រប់រូបមានភាពស្មើគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលការការពារដោយច្បាប់ដូចគ្នា ប្រឆាំងនឹងការរើសអើង និងការញុះញង់ទាំងឡាយណាដែលនាំឱ្យមានការរើសអើង ។

*យល់ឃើញថា* សហប្រជាជាតិបានថ្កោលទោសអាណានិគមនិយម និងការអនុវត្តន៍ការផាត់ចេញ និងការរើសអើងអមជាមួយ ទោះតាមទម្រង់ និងមាននៅទីណាក៏ដោយ និង*យល់ឃើញថា* សេចក្តីប្រកាសនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ ស្តីពីការផ្តល់ឯករាជ្យដល់ប្រទេស និងប្រជាពលរដ្ឋស្ថិតក្រោមអាណានិគម (សេចក្តីសម្រេចរបស់មហាសន្និបាតលេខ១៥១៤(XV)) បានអះអាង និងប្រកាសយ៉ាងឧឡារិកពីភាពចាំបាច់នៃការនាំយកបញ្ហាទាំងនេះ ទៅកាន់ទីបញ្ចប់យ៉ាងឆាប់ និងដោយឥតលក្ខខ័ណ្ឌ ។

*យល់ឃើញថា* សេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៦៣ (សេចក្តីសម្រេចរបស់មហាសន្និបាតលេខ១៩០៤(XVIII)) អះអាងយ៉ាងឧឡារិកអំពីភាពចាំបាច់នៃការលុបបំបាត់ឱ្យបានឆាប់ នូវរាល់ទម្រង់ និងរាល់ការសម្តែង ការរើសអើងពូជសាសន៍ទូទាំងពិភពលោក និងធានាឱ្យមានការយល់ដឹង និងការគោរពដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ។

*ជឿជាក់ថា* រាល់លទ្ធិនៃឧត្តមភាព ដែលផ្អែកលើការបែងចែកពូជសាសន៍ គឺខុសឆ្គងខាងវិទ្យាសាស្ត្រ អាចត្រូវថ្កោលទោសខាងសីលធម៌ នាំឱ្យមានអយុត្តិធម៌ និងគ្រោះថ្នាក់ដល់សង្គម និង*ជឿជាក់ថា* ពុំមានយុត្តិកម្មសម្រាប់ការរើសអើងពូជសាសន៍ក្នុងទ្រឹស្តី ឬក្នុងការអនុវត្តន៍ឡើយ ។

*អះអាងជាថ្មីថា* ការរើសអើងរវាងមនុស្ស និងមនុស្ស ផ្អែកលើពូជសាសន៍ពណ៌សម្បុរ ឬដើមកំណើតជាតិ គឺជាឧបសគ្គដល់ការទាក់ទងជាមិត្តភាព និងសន្តិភាពរវាងប្រជាជាតិនានា និងអាចរំខានដល់សន្តិភាព និងសន្តិសុខរវាងប្រជាជាតិ និងភាពចុះសម្រុងគ្នារវាងមនុស្សរស់នៅក្នុងរដ្ឋជាមួយគ្នា ។

*ជឿជាក់ថា*អត្ថិភាពនៃរបាំងពូជសាសន៍មិនអាចចុះសម្រុងជាមួយនឹងឧត្តមគតិនៃសង្គមមនុស្សបានឡើយ។

*ភ្ញាក់ផ្អើល* ចំពោះការសម្តែងការរើសអើងពូជសាសន៍ នៅមានជាភស្តុតាងក្នុងតំបន់ខ្លះនៃពិភពលោក និងចំពោះនយោបាយរបស់រដ្ឋាភិបាល ដែលឈរលើឧត្តមភាពខាងពូជសាសន៍ ឬការស្អប់ខ្ពើមខាងពូជសាសន៍ ដូចជានយោបាយ*អាផាថែត* ការផាត់ចេញ ឬការបែងចែក ។

*ប្តេជ្ញាចិត្ត* អនុម័តយកវិធានការចាំបាច់ទាំងអស់ ដើម្បីលុបបំបាត់ឱ្យបានឆាប់នូវរាល់ទម្រង់ និងរាល់ការសម្តែងការរើសអើងពូជសាសន៍ និងទប់ស្កាត់ និងប្រយុទ្ធប្រឆាំងទ្រឹស្តី និងការអនុវត្តន៍បែបពូជសាសន៍និយម ដើម្បីបង្កការយោគយល់រវាងពូជសាសន៍ និងពូជសាសន៍ និងស្ថាបនាសហគមន៍អន្តរជាតិមួយ រួចផុតពីគ្រប់ទម្រង់នៃការផាត់ចេញ និងការរើសអើងពូជសាសន៍ ។

*ចងចាំនូវ* អនុសញ្ញាស្តីពីការរើសអើងក្នុងការជួលឱ្យធ្វើការ និងការប្រកបមុខរបរ អនុម័តដោយអង្គការពលកម្មអន្តរជាតិក្នុងឆ្នាំ១៩៥៨ និងអនុសញ្ញាប្រឆាំងនឹងការរើសអើងក្នុងវិស័យអប់រំអនុម័តដោយអង្គការសម្រាប់ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌នៃសហប្រជាជាតិ ក្នុងឆ្នាំ១៩៦០ ។

*ប្រាថ្នា* អនុវត្តគោលការណ៍នានា ដែលចែងក្នុងសេចក្តីប្រកាសរបស់អង្គការសហប្រជាជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងធានាអនុម័តយ៉ាងឆាប់បំផុត នូវវិធានការអនុវត្តន៍សម្រាប់ទិសដៅនេះ ។

*បានព្រមព្រៀងគ្នាដូចតទៅ :*

## ផ្នែកទី ១

## មាត្រា ១

១. ក្នុងអនុសញ្ញានេះ ពាក្យ "ការរើសអើងពូជសាសន៍" មានន័យថា ការប្រកាន់បែងចែក ការផាត់ចេញ ការរឹតត្បិត ឬការនិយម ផ្អែកលើពូជសាសន៍ ពណ៌សម្បុរ បុព្វញាតិ ឬដើមកំណើតជាតិ ឬជាតិពន្ធុ ដែលមានទិសដៅ ឬអានុភាព បំផ្លាញ ឬបន្ថយការទទួលស្គាល់ ការមាន ឬការប្រើប្រាស់ក្នុងល័ក្ខខ័ណ្ឌសមភាពនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ខាងវិស័យនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ឬវិស័យដទៃទៀតនៃជីវភាពសាធារណៈ ។

២. អនុសញ្ញានេះមិនអនុវត្តទៅលើការបែងចែក ការផាត់ចេញ ការរឹតត្បិត ឬការនិយមរវាងប្រជាពលរដ្ឋខ្លួន និងមិនមែនជាប្រជាពលរដ្ឋខ្លួនដែលធ្វើឡើងដោយរដ្ឋភាគីនៃអនុសញ្ញានេះឡើយ ។

៣. គ្មានបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ អាចត្រូវបានបកស្រាយ ទោះតាមវិធីណាក៏ដោយ ថាប៉ះពាល់ដល់បទបញ្ញត្តិច្បាប់របស់រដ្ឋភាគីនៃអនុសញ្ញានេះ ស្ដីពីសញ្ជាតិ ភាពជាប្រជាពលរដ្ឋ ឬការចូលសញ្ជាតិ ឱ្យតែបទបញ្ញត្តិច្បាប់ទាំងនោះមិនរើសអើងចំពោះសញ្ជាតិពិសេសណាមួយ ។

៤. វិធានការពិសេសនានាដែលបានធ្វើឡើង ក្នុងគោលបំណងធានាតែម្យ៉ាងគត់ ដល់ការរីកចម្រើនសមស្របរបស់ក្រុម ឬបុគ្គលជនជាតិ ឬពូជសាសន៍ខ្លះ ដែលត្រូវការនូវការការពារជាចាំបាច់ ដើម្បីធានាឱ្យក្រុម ឬបុគ្គលទាំងនោះបានទទួល ឬប្រើប្រាស់សិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ក្នុងល័ក្ខខ័ណ្ឌស្មើភាព ដោយមិនត្រូវចាត់ទុកជាវិធានការរើសអើងពូជសាសន៍ឡើយ ឱ្យតែវិធានការទាំងនោះ មិនបង្កឱ្យមានការរក្សាសិទ្ធិដាច់ដោយឡែក សម្រាប់ក្រុមពូជសាសន៍ផ្សេងគ្នា និងឱ្យតែវិធានការទាំងនោះ មិនត្រូវបានបន្តធ្វើ បន្ទាប់ពីទិសដៅនៃវិធានការ ត្រូវបានសម្រេចហើយ ។

## មាត្រា ២

១. រដ្ឋភាគី ផ្តន្ទាទោសការរើសអើងពូជសាសន៍ និងសន្យាធ្វើតាមគ្រប់វិធីសមស្រប និងដោយមិនពន្យារពេល នូវនយោបាយលប់បំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងបង្កការយោគយល់រវាងពូជសាសន៍ទាំងអស់ ហើយដើម្បីសំរេចទិសដៅនេះ :

(ក) រដ្ឋភាគីនីមួយៗ សន្យាមិនធ្វើអំពើ ឬការអនុវត្តន៍ណាមួយនៃការរើសអើងពូជសាសន៍ប្រឆាំងនឹងមនុស្ស ក្រុមមនុស្ស ឬស្ថាប័ន និងធានាថា អាជ្ញាធរ និងស្ថាប័នសាធារណៈទាំងអស់ ទាំងថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ធ្វើស្របតាមកាតព្វកិច្ចនេះ ។

(ខ) រដ្ឋភាគីនីមួយៗ សន្យាមិនលើកទឹកចិត្ត ការពារ ឬគាំទ្រដល់ការរើសអើងពូជសាសន៍ ដែលធ្វើដោយមនុស្សម្នាក់ ឬអង្គការណាមួយឡើយ ។

(គ) រដ្ឋភាគីនីមួយៗ ត្រូវចាត់វិធានការស័ក្តិសិទ្ធិ ដើម្បីពិនិត្យឡើងវិញនូវនយោបាយរបស់រដ្ឋាភិបាល ទាំងថ្នាក់ជាតិ និងមូលដ្ឋាន និងដើម្បីកែប្រែ និរាករណ៍ ឬដាក់ឱ្យមោឃៈនូវច្បាប់ និងបទបញ្ញត្តិណាដែលមានអានុភាពបង្កើត ឬបន្តការរើសអើងពូជសាសន៍ ទោះមាននៅទីណាក៏ដោយ ។

(ឃ) រដ្ឋភាគីនីមួយៗ តាមគ្រប់មធ្យោបាយសមស្រប រួមមានវិធានការខាងផ្លូវច្បាប់ផង តាមដែលស្ថានភាពតម្រូវ ត្រូវហាមឃាត់ និងបញ្ចប់ការរើសអើងពូជសាសន៍ ដែលធ្វើដោយមនុស្ស ក្រុមមនុស្ស ឬអង្គការណាក៏ដោយ ។

(ង) រដ្ឋភាគីនីមួយៗសន្យាបង្កលក្ខណៈតាមករណីសមស្របឱ្យមានអង្គការ និងចលនាសមាហរណកម្មពហុពូជសាសន៍ និងមធ្យោបាយដទៃទៀត សម្រាប់ការលុបបំបាត់របាំងរវាងពូជសាសន៍ និងបន្ទុចបង្អាក់ អ្វីដែលមានទំនោរពង្រឹងការបែងចែកពូជសាសន៍ ។

២. រដ្ឋភាគី បើកាលៈទេសៈតម្រូវ ក្នុងវិស័យសង្គមកិច្ច សេដ្ឋកិច្ច វប្បធម៌ និងវិស័យដទៃទៀត ត្រូវចាត់វិធានការពិសេស និងជាក់ស្តែង ដើម្បីធានាការអភិវឌ្ឍន៍ និងការការពារគ្រប់គ្រាន់ដល់ក្រុមពូជសាសន៍ខ្លះ ឬបុគ្គលក្នុងក្រុមទាំងនោះ ក្នុងគោលបំណងធានាឱ្យពួកគេ ទទួលបានពេញលេញ និងស្មើភាពនូវសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន។ វិធានការទាំងនេះ ទោះក្នុងករណីណាក៏ដោយ មិនតម្រូវឱ្យរក្សាទុកសិទ្ធិមិនស្មើភាព និងដាច់ដោយឡែក សម្រាប់ក្រុមពូជសាសន៍ផ្សេងគ្នា បន្ទាប់ពីទិសដៅនៃវិធានការ ត្រូវបានសម្រេចហើយ ។

## មាត្រា ៣

រដ្ឋភាគីផ្តន្ទាទោសជាពិសេសដល់ការផាត់ចេញខាងពូជសាសន៍ និងអាផាថេត និងសន្យាបង្ការ ហាមឃាត់ និងលុបបំបាត់ការអនុវត្តន៍ប្រភេទនេះ លើទឹកដីដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួន ។

## មាត្រា ៤

រដ្ឋភាគីផ្តន្ទាទោសការឃោសនាទាំងអស់ និងអង្គការទាំងអស់ដែលយកគំនិត ឬទ្រឹស្តីផ្អែកលើឧត្តមភាព ពូជសាសន៍មួយ ឬក្រុមមួយនៃមនុស្សដែលមានពណ៌សម្បុរមួយ ឬដើមកំណើតជនជាតិមួយ ឬដែលប៉ុនប៉ងការពារ ឬលើកស្ទួយការស្អប់ខ្ពើម និងការរើសអើងពូជសាសន៍ក្នុងទម្រង់ណាមួយ ។ រដ្ឋភាគីសន្យាអនុម័តជាបន្ទាន់នូវវិធានការជាវិជ្ជមាន សំដៅលុបបំបាត់រាល់ការញុះញង់ ឬរាល់អំពើនាំឱ្យមានការរើសអើងពូជសាសន៍ ហើយដើម្បីទិសដៅនេះ ត្រូវឈរលើគោលការណ៍ដែលបានចែងនៅក្នុងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងសិទ្ធិដែលមានចែងច្បាស់លាស់ក្នុងមាត្រា៥ នៃអនុសញ្ញានេះ ។ រដ្ឋភាគី សន្យាជាពិសេស :

(ក) ប្រកាសពីបទល្មើសដែលត្រូវផ្តន្ទាទោសដោយច្បាប់ ការសាបព្រោះ

ផ្សព្វផ្សាយទាំងអស់នូវគំនិតទាំងឡាយ ដែលផ្អែកលើឧត្តមភាព ឬការស្អប់ខ្ពើម ការញុះញង់ទាំងអស់ដែលនាំឱ្យមានការរើសអើងពូជសាសន៍ ក៏ដូចជារាល់អំពើហិង្សា ឬការញុះញុងឱ្យមានអំពើបែបនេះប្រឆាំងពូជសាសន៍ ឬក្រុមមនុស្សណាមួយដែលមានពណ៌សម្បុរផ្សេង ឬដើមកំណើតជាតិផ្សេង និងការជួយដល់សកម្មភាពខាងពូជសាសន៍និយម រួមមានហិរញ្ញប្បទានផង ។

(ខ) ប្រកាសថាខុសច្បាប់ និងហាមឃាត់អង្គការ សកម្មភាពមានការចាត់តាំង និងរាល់សកម្មភាពឃោសនាដែលលើកស្ទួយ និងញុះញង់ឱ្យមានការរើសអើងពូជសាសន៍ និងប្រកាសថាការចូលរួមជាមួយអង្គការ ឬសកម្មភាពបែបនេះ គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសដោយច្បាប់ ។

(គ) មិនអនុញ្ញាតឱ្យអាជ្ញាធរ ឬស្ថាប័នសាធារណៈទាំងថ្នាក់ជាតិ ឬថ្នាក់មូលដ្ឋាន លើកស្ទួយ ឬញុះញង់ឱ្យមានការរើសអើងពូជសាសន៍ ។

## មាត្រា ៥

ស្របតាមកាតព្វកិច្ចជាមូលដ្ឋានដែលបានចែងក្នុងមាត្រា២ នៃអនុសញ្ញានេះ រដ្ឋភាគីសន្យាហាមឃាត់ និងលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ និងសន្យាធានាឱ្យមនុស្សម្នាក់ៗ មានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដោយគ្មានការប្រកាន់បែងចែក មានជាអាទិ៍ ពូជសាសន៍ ពណ៌សម្បុរ ឬដើមកំណើតជាតិ ឬជនជាតិជាពិសេសក្នុងការអាស្រ័យផលសិទ្ធិដូចខាងក្រោម :

(ក) សិទ្ធិទទួលបានការប្រព្រឹត្តិមកលើខ្លួនស្មើគ្នាចំពោះមុខសាលាជំរះក្តី និងស្ថាប័នទាំងឡាយដែលផ្តល់យុត្តិធម៌ ។

(ខ) សិទ្ធិមានសន្តិសុខបុគ្គល និងការការពារដោយរដ្ឋប្រឆាំងនឹងការរំលោភ ឬការបំពាបំពានរាងកាយពីសំណាក់មន្ត្រីរាជការរបស់រដ្ឋាភិបាល ឬពីសំណាក់ក្រុមបុគ្គល ឬស្ថាប័នណាមួយ ។

(គ) សិទ្ធិនយោបាយ ជាពិសេសសិទ្ធិចូលរួមការបោះឆ្នោត សិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះបោះឆ្នោត តាមប្រព័ន្ធនៃការបោះឆ្នោតជាសកល និងស្មើភាព សិទ្ធិចូលរួមក្នុងរដ្ឋាភិបាល ក៏ដូចជាក្នុងការដឹកនាំការងារសាធារណៈនៅគ្រប់ជាន់ថ្នាក់ និងមានលទ្ធភាពស្មើគ្នាក្នុងការចូលបំរើការងារសាធារណៈ ។

(ឃ) សិទ្ធិពលរដ្ឋដទៃទៀត ជាពិសេស :

(i) សិទ្ធិដើរហើរ និងមានទិវេសនដ្ឋានដោយសេរីនៅក្នុងព្រំដែននៃរដ្ឋមួយ ។

(ii) សិទ្ធិចាកចេញពីប្រទេសណាមួយ រួមទាំងប្រទេសរបស់ខ្លួនផង និងវិលត្រឡប់មកប្រទេសខ្លួនវិញ។

(iii) សិទ្ធិមានសញ្ជាតិមួយ ។

(iv) សិទ្ធិរៀបអាពាហ៍ពិពាហ៍ និងជ្រើសរើសគូស្រករ ។

(v) សិទ្ធិមានកម្មសិទ្ធិតែម្នាក់ឯង ក៏ដូចជារួមជាមួយអ្នកដទៃ ។

(vi) សិទ្ធិជាទាយាទ ។

(vii) សិទ្ធិក្នុងការគិត មានសម្បជញ្ញៈ និងមានជំនឿសាសនាដោយសេរី ។

(viii) សិទ្ធិមានមតិ និងបញ្ចេញមតិដោយសេរី ។

(ix) សិទ្ធិមានសេរីភាពក្នុងការប្រជុំ និងធ្វើសមាគមដោយសន្តិវិធី ។

(ង) សិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ជាពិសេសៈ

(i) សិទ្ធិធ្វើការងារ សិទ្ធិជ្រើសរើសការងារដោយសេរី សិទ្ធិទទួលបានល័ក្ខខ័ណ្ឌធ្វើការត្រឹមត្រូវ និងប្រកបដោយអំណោយផល សិទ្ធិទទួលបានការការពារប្រឆាំងការគ្មានការងារធ្វើ សិទ្ធិទទួលប្រាក់ឈ្នួលស្មើគ្នាចំពោះការងារដូចគ្នា សិទ្ធិទទួលបានប្រាក់បំណាច់សមស្រប និងជាទីពេញចិត្ត ។

(ii) សិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីព ។

(iii) សិទ្ធិមានផ្ទះជ្រកកោណ ។

(iv) សិទ្ធិមានសុខភាព ការព្យាបាលជំងឺ សន្តិសុខសង្គម និងសេវាសង្គមកិច្ច។

(v) សិទ្ធិទទួលបានការអប់រំ និងការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

(vi) សិទ្ធិចូលរួមក្នុងសកម្មភាពវប្បធម៌ ក្នុងល័ក្ខខ័ណ្ឌសមភាព ។

**(ច)** សិទ្ធិចេញចូលទីកន្លែង ឬទទួលសេវា ដែលដាក់ឱ្យប្រើប្រាស់ដោយសាធារណៈជនទូទៅ ដូចជាការដឹកជញ្ជូន សណ្ឋាគារ ភោជនីយដ្ឋាន កន្លែងលក់កាហ្វេ រោងល្ខោន និងសួនច្បារ ។

## មាត្រា ៦

រដ្ឋភាគី ត្រូវធានាថា មនុស្សគ្រប់រូបដែលស្ថិតក្រោមដែនសមត្ថកិច្ចរបស់ខ្លួនទទួលបានការការពារ និងការដោះស្រាយសំក្តិសិទ្ធិតាមរយៈតុលាការជាតិ និងស្ថាប័នរដ្ឋមានសមត្ថកិច្ចផ្សេងទៀត ប្រឆាំងនឹងអំពើរើសអើងពូជសាសន៍ ដែលរំលោភសិទ្ធិមនុស្ស និងសេរីភាពមូលដ្ឋាន ផ្ទុយនឹងអនុសញ្ញានេះ និងមានសិទ្ធិសុំឱ្យតុលាការទាំងនេះ ផ្ដល់សំណង ឬការជួសជុលត្រឹមត្រូវ និងគ្រប់គ្រាន់ ចំពោះការខូចខាតដែលបណ្ដាលមកពីការរើសអើងពូជសាសន៍ ។

## មាត្រា ៧

រដ្ឋភាគីសន្យាចាត់វិធានការជាបន្ទាន់ និងស័ក្តិសិទ្ធិ ពិសេសក្នុងវិស័យសិក្សាអប់រំ វប្បធម៌ និងព័ត៌មាន ដើម្បីប្រយុទ្ធប្រឆាំងនឹងទស្សនៈលំអៀង ដែលនាំឱ្យមានការរើសអើងពូជសាសន៍ និងដើម្បីបង្កអំណោយផលដល់ការយោគយល់គ្នា ការអត់ឱនឱ្យគ្នា និងមិត្តភាពរវាងប្រជាជាតិ និងក្រុមពូជសាសន៍ ឬក្រុមជនជាតិ ក៏ដូចជាដើម្បីផ្សព្វផ្សាយគោលបំណង និងគោលការណ៍នៃធម្មនុញ្ញសហប្រជាជាតិ សេចក្តី

ប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស សេចក្ដីប្រកាសរបស់អង្គការសហប្រជាជាតិ ស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ ហើយនិងអនុសញ្ញានេះ ។

## ផ្នែកទី ២

### មាត្រា ៨

១. គណៈកម្មាធិការលុបបំបាត់ការរើសអើងពូជសាសន៍ (ចាប់ពីនេះទៅហៅថាគណៈកម្មាធិការ)ត្រូវបង្កើតឡើង ។ គណៈកម្មាធិការនេះ មានអ្នកជំនាញ១៨រូប ដែលមានជំហរសីលធម៌ខ្ពស់ និងមិនលំអៀង និងដែលជ្រើសរើសក្នុងការបោះឆ្នោតដោយរដ្ឋភាគី ក្នុងចំណោមជនជាតិរបស់ខ្លួន និងត្រូវធ្វើការ ក្នុងឋានៈជាបុគ្គលឯកជន ដោយត្រូវធ្វើការពិចារណាបែងចែកតាមភូមិសាស្ត្រដោយសមធម៌ និងឱ្យមានតំណាងទម្រង់ផ្សេងៗនៃអារ្យធម៌ ព្រមទាំងទៅតាមប្រព័ន្ធច្បាប់ធំៗផង ។

២. សមាជិកគណៈកម្មាធិការត្រូវជ្រើសរើសតាមការបោះឆ្នោតដោយសម្ងាត់ពីបញ្ជីរាយនាមបេក្ខជនដែលជ្រើសតាំងដោយរដ្ឋភាគី ។ រដ្ឋភាគីនីមួយៗ អាចជ្រើសតាំងបេក្ខជនម្នាក់ ក្នុងចំណោមជនជាតិរបស់ខ្លួន ។

៣. ការបោះឆ្នោតលើកដំបូង ត្រូវធ្វើឡើង៦ខែ ក្រោយកាលបរិច្ឆេទនៃការចូលជាធរមាននៃអនុសញ្ញានេះ ។ យ៉ាងតិច៣ខែ មុនកាលបរិច្ឆេទនៃការបោះឆ្នោតនីមួយៗ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវចេញលិខិតអញ្ជើញរដ្ឋភាគីឱ្យដាក់ស្នើឈ្មោះបេក្ខជនរបស់ខ្លួន ក្នុងរយៈពេល២ខែ ។ អគ្គលេខាធិការ ត្រូវរៀបចំបញ្ជីឈ្មោះតាមលំដាប់អក្ខរក្រម នៃបេក្ខជនទាំងអស់ ដែលបានដាក់ស្នើដោយរដ្ឋភាគីដោយបញ្ជាក់ឈ្មោះរដ្ឋភាគី ដែលបានជ្រើសតាំងបេក្ខជន ហើយផ្ញើបញ្ជីនេះទៅគ្រប់រដ្ឋភាគីទាំងអស់ ។

៤. ការបោះឆ្នោតជ្រើសរើសសមាជិកគណៈកម្មាធិការត្រូវធ្វើក្នុងសម័យប្រជុំ

នៃរដ្ឋភាគី តាមការកោះអញ្ជើញដោយអគ្គលេខាធិការ នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។ កូរ៉ុមសម្រាប់កិច្ចប្រជុំ គឺពីរភាគបីនៃរដ្ឋភាគី ។ បេក្ខជនដែលជាប់ជាសមាជិកគណៈកម្មាធិការ ត្រូវតែជាបេក្ខជនដែលទទួលបានសម្លេងច្រើនបំផុត និងសម្លេងភាគច្រើនដាច់ខាតពីតំណាងរបស់រដ្ឋភាគីដែលមានវត្តមាននិងបានបោះឆ្នោត។

៥. (ក) សមាជិកគណៈកម្មាធិការ ត្រូវជ្រើសរើសតាមការបោះឆ្នោតសម្រាប់រយៈពេល៤ឆ្នាំ ។ ប៉ុន្តែ អាណត្តិសមាជិក៩រូប ដែលជាប់នៅពេលបោះឆ្នោតលើកទី១ ត្រូវផុតកំណត់ក្នុងរយៈពេល២ឆ្នាំ ហើយឈ្មោះសមាជិកទាំង៩រូបនេះ ត្រូវចាប់ឆ្នោតជ្រើសរើសដោយប្រធានអង្គប្រជុំភ្លាមៗ បន្ទាប់ពីការបោះឆ្នោតលើកទី១ ។

(ខ) ដើម្បីបំពេញកន្លែងទំនេរដោយចៃដន្យ រដ្ឋភាគីដែលមានអ្នកជំនាញការឈប់បំពេញមុខងាររបស់ខ្លួន ជាសមាជិកគណៈកម្មាធិការ ត្រូវតែងតាំងអ្នកជំនាញម្នាក់ទៀតក្នុងចំណោមជនជាតិរបស់ខ្លួន ដោយមានការយល់ព្រមពីគណៈកម្មាធិការ។

(៦) រដ្ឋភាគីត្រូវទទួលបន្ទុកខ្លួនឯង លើចំណាយរបស់សមាជិកគណៈកម្មាធិការ សម្រាប់រយៈពេលសមាជិកគណៈកម្មាធិការបំពេញការងារ ។

## មាត្រា ៩

១. រដ្ឋភាគី សន្យាដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដើម្បីគណៈកម្មាធិការ ពិនិត្យនូវរបាយការណ៍ស្តីពីវិធានការខាងនីតិកម្ម តុលាការ រដ្ឋបាលឬវិធានការផ្សេងទៀតដែលបានអនុម័ត និងផ្តល់អានុភាពដល់បទបញ្ញត្តិនៃអនុសញ្ញានេះ :

(ក) នៅក្នុងរយៈពេល១ឆ្នាំ គិតចាប់ពីការចូលជាធរមាននៃអនុសញ្ញានេះសម្រាប់រដ្ឋពាក់ព័ន្ធ និង

(ខ) បន្ទាប់មកទៀត រាល់២ឆ្នាំម្តង និងនៅគ្រប់ពេលដែលគណៈកម្មាធិការសុំឱ្យធ្វើ ។ គណៈកម្មាធិការអាចសុំព័ត៌មានបន្ថែមពីរដ្ឋភាគីបាន ។

២.  គណៈកម្មាធិការ ត្រូវដាក់របាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាពរបស់ខ្លួន តាមរយៈអគ្គលេខាធិការ ជូនទៅមហាសន្និបាតអង្គការសហប្រជាជាតិ និងអាចផ្តល់យោបល់ និងអនុសាសន៍ទូទៅផ្អែកលើការពិនិត្យរបាយការណ៍ និងព័ត៌មានទទួលបានពីរដ្ឋភាគី ។ ការផ្តល់យោបល់ និងអនុសាសន៍ទូទៅទាំងនេះ ត្រូវដាក់ជូនមហាសន្និបាត ព្រមជាមួយមូលវិចាររបស់រដ្ឋភាគី បើសិនជាមាន ។

## មាត្រា ១០

១.  គណៈកម្មាធិការ ត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

២.  គណៈកម្មាធិការ ត្រូវបោះឆ្នោតជ្រើសរើសមន្ត្រីការិយាល័យរបស់ខ្លួន សម្រាប់រយៈពេល២ឆ្នាំ ។

៣.  លេខាធិការដ្ឋានរបស់គណៈកម្មាធិការ ត្រូវបានផ្តល់ឱ្យដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ

៤.  ការប្រជុំគណៈកម្មាធិការ ជាធម្មតា ធ្វើនៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

## មាត្រា ១១

១.  បើរដ្ឋភាគីណាមួយយល់ឃើញថា រដ្ឋភាគីមួយទៀតមិនអនុវត្តបទបញ្ញត្តិនៃអនុសញ្ញានេះ រដ្ឋនោះ អាចលើកយកបញ្ហានេះដាក់ជូនគណៈកម្មាធិការ។ គណៈកម្មាធិការ ត្រូវបញ្ជូនបណ្តឹងនេះទៅរដ្ឋភាគីពាក់ព័ន្ធ។ ក្នុងរយៈពេល៣ខែ រដ្ឋចុងបណ្តឹង ត្រូវដាក់ជូនគណៈកម្មាធិការ នូវការពន្យល់ ឬសេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សរ ដោយបំភ្លឺបញ្ហា រួមទាំងការដោះស្រាយ បើសិនជាមាន ដែលរដ្ឋចុងបណ្តឹងបានធ្វើ ។

២.  បើបញ្ហា មិនត្រូវបានដោះស្រាយឱ្យពេញចិត្តសម្រាប់រដ្ឋពាក់ព័ន្ធទាំងពីរ

តាមការចរចាទ្វេភាគី ឬតាមនីតិវិធីណាមួយបានទេ ក្នុងរយៈពេល៦ខែ បន្ទាប់ពីរដ្ឋចុងបណ្តឹងបានទទួលបណ្តឹងទីមួយ ហើយរដ្ឋភាគីណាមួយក៏បាន មានសិទ្ធិលើកយកបញ្ហានោះ ដាក់ជូនគណៈកម្មាធិការជាថ្មី ដោយការជូនដំណឹងទៅគណៈកម្មាធិការ និងដល់រដ្ឋម្ខាងទៀត ។

៣. គណៈកម្មាធិការ ត្រូវដោះស្រាយបញ្ហាដែលដាក់ជូនមកខ្លួន ស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ក្រោយពីខ្លួនបានដឹងច្បាស់ថា វិធីដោះស្រាយទាំងអស់ដែលមាននៅក្នុងស្រុក បានយកមកប្រើអស់ហើយ ក្នុងករណីនេះ ស្របតាមគោលការណ៍នៃច្បាប់អន្តរជាតិ ដែលត្រូវបានទទួលស្គាល់ជាទូទៅ ។ វិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ ។

៤. ចំពោះគ្រប់សំណុំរឿងដែលបញ្ជូនមក គណៈកម្មាធិការ អាចសុំរដ្ឋភាគីពាក់ព័ន្ធឱ្យផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

៥. នៅពេលគណៈកម្មាធិការពិនិត្យសំណុំរឿងណាមួយស្របតាមមាត្រានេះ រដ្ឋភាគីពាក់ព័ន្ធ មានសិទ្ធិចាត់តំណាងម្នាក់ឱ្យចូលរួម តែពុំមានសិទ្ធិបោះឆ្នោត ក្នុងការងាររបស់គណៈកម្មាធិការនៅគ្រប់ពេលនៃការពិនិត្យពិភាក្សាលើករណីនេះឡើយ។

## មាត្រា ១២

១.(ក) បន្ទាប់ពីគណៈកម្មាធិការ បានទទួល និងប្រមូលផ្តុំតាមលំដាប់លំដោយ នូវព័ត៌មានទាំងអស់ ដែលខ្លួនយល់ថាចាំបាច់ហើយ ប្រធានគណៈកម្មាធិការត្រូវតែងតាំងគណៈកម្មការចំពោះកិច្ចមួយ (ដែលពីនេះតទៅហៅថាគណៈកម្មការ) ដែលមានសមាសភាព ៥រូប ដែលអាចជាសមាជិក ឬអាចមិនមែនជាសមាជិកគណៈកម្មាធិការ។ សមាជិកគណៈកម្មការត្រូវតែងតាំងដោយមានការយល់ព្រមជាឯកច្ឆ័ន្ទពីភាគីមានទំនាស់ និងត្រូវដាក់សេវារបស់ខ្លួនឱ្យរដ្ឋភាគីពាក់ព័ន្ធប្រើប្រាស់ ដើម្បីរកដំណោះស្រាយស្រុះស្រួលលើបញ្ហា ដោយគោរពតាមអនុសញ្ញានេះ ។

១. បើរដ្ឋភាគីមានទំនាស់ មិនឈានដល់ការព្រមព្រៀងទាំងស្រុង ឬផ្នែកខ្លះ លើសមាសភាពគណៈកម្មការ ក្នុងរយៈពេល៣ខែទេ សមាជិកគណៈកម្មការណាដែល មិនបានទទួលការយល់ព្រមពីរដ្ឋភាគីមានទំនាស់ ត្រូវដាក់ឱ្យជ្រើសរើសតាមការបោះឆ្នោតជាសម្ងាត់ ដោយយកសម្លេងភាគច្រើនពីរភាគបី នៃចំណោមសមាជិកគណៈកម្មាធិការ ។

២. សមាជិកគណៈកម្មការ ត្រូវធ្វើការក្នុងឋានៈជាបុគ្គលឯកជន។ សមាជិកគណៈកម្មការ មិនត្រូវជាជនជាតិនៃរដ្ឋភាគីមានទំនាស់ ឬនៃរដ្ឋមិនមែនភាគីនៃអនុសញ្ញានេះឡើយ ។

៣. គណៈកម្មការ ត្រូវបោះឆ្នោតរើសប្រធាន និងត្រូវអនុម័តបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន ។

៤. ការប្រជុំគណៈកម្មការ ត្រូវធ្វើជាធម្មតានៅទីស្នាក់ការអង្គការសហប្រជាជាតិ ឬនៅកន្លែងសមស្របផ្សេងទៀត កំណត់ដោយគណៈកម្មការ ។

៥. លេខាធិការដ្ឋាន ដែលកំណត់ស្របតាមមាត្រា១០ កថាខណ្ឌ៣ នៃអនុសញ្ញានេះ ត្រូវជួយគណៈកម្មការ នៅពេលទំនាស់រវាងរដ្ឋភាគី ឈានដល់ការបង្កើតឱ្យមានគណៈកម្មការ ។

៦. រដ្ឋភាគីមានទំនាស់ ត្រូវបែងចែកស្មើគ្នា លើចំណាយសម្រាប់សមាជិកគណៈកម្មការ ស្របតាមការប៉ាន់ស្មាន កំណត់ដោយ អគ្គលេខាធិការអង្គការសហប្រជាជាតិ ។

៧. បើចាំបាច់ អគ្គលេខាធិការ មានសិទ្ធិចេញចំណាយជួសសមាជិកគណៈកម្មការ មុនពេលសងមកវិញ ដោយរដ្ឋភាគីមានទំនាស់ ស្របតាមកថាខណ្ឌ៦ នៃមាត្រានេះ ។

៨. ព័ត៌មានដែលគណៈកម្មាធិការទទួល និងប្រមូលបាន ត្រូវដាក់ឱ្យគណៈកម្មការប្រើប្រាស់ ហើយគណៈកម្មការ អាចសុំឱ្យរដ្ឋភាគីពាក់ព័ន្ធ ផ្តល់ព័ត៌មានពាក់ព័ន្ធផ្សេងទៀត ។

## មាត្រា ១៣

១. នៅពេលគណៈកម្មការ បានសិក្សាបញ្ហាសព្វគ្រប់ហើយ គណៈកម្មការត្រូវរៀបចំ និងដាក់ជូនប្រធានគណៈកម្មាធិការ នូវរបាយការណ៍មួយ ដែលបង្ហាញសេចក្តីសន្និដ្ឋានលើបញ្ហាអង្គហេតុទាក់ទងនឹងចំណុចវិវាទ រវាងភាគី និងកំណត់អនុសាសន៍ ដែលគណៈកម្មាធិការយល់ឃើញថា សមស្របសម្រាប់ដោះស្រាយទំនាស់ដោយស្រុះស្រួលគ្នា ។

២. ប្រធានគណៈកម្មាធិការ ត្រូវផ្ញើរបាយការណ៍របស់គណៈកម្មការជូនទៅភាគីមានទំនាស់។ រដ្ឋភាគីទាំងនេះ ត្រូវជូនដំណឹងទៅប្រធានគណៈកម្មាធិការ ក្នុងរយៈពេល៣ខែ ថាខ្លួនព្រមទទួល ឬមិនព្រមទទួលយកអនុសាសន៍ដែលកំណត់ក្នុងរបាយការណ៍របស់គណៈកម្មការ ។

៣. បើផុតរយៈពេលដែលបានកំណត់ក្នុងកថាខណ្ឌ២ នៃមាត្រានេះ ប្រធានគណៈកម្មាធិការ ត្រូវផ្ញើរបាយការណ៍របស់គណៈកម្មការ និងសេចក្តីប្រកាសរបស់រដ្ឋភាគីពាក់ព័ន្ធ ជូនទៅរដ្ឋភាគីផ្សេងទៀតនៃអនុសញ្ញានេះ ។

## មាត្រា ១៤

១. រដ្ឋភាគី អាចប្រកាសគ្រប់ពេលវេលាថា ខ្លួនទទួលស្គាល់សមត្ថកិច្ចរបស់គណៈកម្មាធិការ ក្នុងការទទួល និងពិនិត្យបណ្តឹងរបស់បុគ្គល ឬក្រុមបុគ្គលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដែលអះអាងថា ជាជនរងគ្រោះពីការរំលោភដោយរដ្ឋភាគីទៅលើសិទ្ធិណាមួយដែលមានចែងនៅក្នុងអនុសញ្ញានេះ ។ គណៈកម្មាធិការនឹងមិនទទួលយកបណ្តឹងពាក់ព័ន្ធនឹងរដ្ឋភាគី ដែលមិនបានធ្វើសេចក្តីប្រកាសនេះឡើយ។

២. រដ្ឋភាគីណាដែលធ្វើសេចក្តីប្រកាស ស្របតាមកថាខណ្ឌ១នៃមាត្រានេះ អាចបង្កើត ឬបង្ហាញឈ្មោះស្ថាប័នមួយ ក្នុងលំដាប់គតិយុត្តិថ្នាក់ជាតិរបស់ខ្លួនដែលមានសមត្ថកិច្ចទទួល និងពិនិត្យបណ្តឹងទាមទាររបស់បុគ្គល ឬក្រុមបុគ្គលដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងដែលអះអាងថា ជាជនរងគ្រោះដោយការរំលោភសិទ្ធិណាមួយដែលមានចែងក្នុងអនុសញ្ញានេះ ហើយដែលបានប្រើអស់ដំណោះស្រាយក្នុងស្រុកដែលមាន ។

៣. សេចក្តីប្រកាសដែលធ្វើស្របតាមកថាខណ្ឌ១ នៃមាត្រានេះ និងឈ្មោះស្ថាប័នណាមួយដែលបានបង្កើត ឬបង្ហាញស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ត្រូវដំកល់ទុកដោយរដ្ឋភាគីពាក់ព័ន្ធ នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវបញ្ជូនច្បាប់ចម្លងនៃសេចក្តីប្រកាស និងឈ្មោះស្ថាប័នទៅជូនរដ្ឋភាគីផ្សេងទៀត ។ សេចក្តីប្រកាសអាចដកវិញបានគ្រប់ពេលដោយការជូនដំណឹងទៅអគ្គលេខាធិការ ប៉ុន្តែការដកនេះ មិនប៉ះពាល់បញ្ហាដែលគណៈកម្មាធិការបានទទួលរួចហើយឡើយ ។

៤. ស្ថាប័នដែលបានបង្កើត ឬបង្ហាញស្របតាមកថាខណ្ឌ២ នៃមាត្រានេះ ត្រូវរក្សាសៀវភៅចុះបញ្ជីបណ្តឹងទាមទារ ហើយច្បាប់ចម្លងនៃសៀវភៅចុះបញ្ជីដែលមានការបញ្ជាក់ស្របតាមច្បាប់ដើម ត្រូវដំកល់ទុកនៅនឹងអគ្គលេខាធិការ រៀងរាល់ឆ្នាំតាមរយៈខ្សែបណ្តាញសមស្រប ក្នុងន័យថា ខ្លឹមសារនៃច្បាប់ចម្លង មិនត្រូវឱ្យដឹងជាសាធារណៈឡើយ ។

៥. បើមិនពេញចិត្តនឹងស្ថាប័នដែលបង្កើត ឬបង្ហាញស្របតាមកថាខណ្ឌ២ នៃមាត្រានេះទេ អ្នកដាក់បណ្តឹងទាមទារ មានសិទ្ធិក្នុងរយៈពេល៦ខែ ប្តឹងអំពីបញ្ហានេះ ទៅគណៈកម្មាធិការ ។

៦. (ក) គណៈកម្មាធិការ ត្រូវបញ្ជូនជាសម្ងាត់នូវបណ្តឹងណាដែលផ្ញើមកឱ្យខ្លួន ទៅរដ្ឋភាគីដែលជាប់ចោទថាបានរំលោភបទបញ្ញត្តិណាមួយនៃអនុសញ្ញានេះ ប៉ុន្តែអត្តសញ្ញាណរបស់បុគ្គល ឬក្រុមបុគ្គលពាក់ព័ន្ធ មិនត្រូវប្រាប់ឱ្យដឹងឡើយ បើគ្មានការយល់ព្រមជាក់លាក់ពីបុគ្គលនេះ ឬក្រុមបុគ្គលនេះ ។ គណៈកម្មាធិការ មិនទទួលបណ្តឹងអនាមិកទេ ។

(ខ) ក្នុងរយៈពេល៣ខែ រដ្ឋចុងចោទ ត្រូវដាក់ការពន្យល់ ឬសេចក្តីថ្លែងការណ៍ជាលាយល័ក្ខណ៍អក្សរ បំភ្លឺអំពីបញ្ហា និងការដោះស្រាយ ប្រសិនជាមានដែលរដ្ឋចុងចោទបានធ្វើឡើងហើយ ។

៧. (ក) គណៈកម្មាធិការ ត្រូវពិនិត្យបណ្តឹងទាំងឡាយ ស្របតាមព័ត៌មានដែលខ្លួនបានទទួលពីរដ្ឋភាគីពាក់ព័ន្ធ និងពីអ្នកប្តឹងទាមទារ ។ គណៈកម្មាធិការ មិនពិនិត្យបណ្តឹងពីអ្នកប្តឹងទាមទារណាដែលមិនបានធានាអះអាងថា ខ្លួនបានប្រើអស់នូវការដោះស្រាយក្នុងស្រុកដែលមាន។ ប៉ុន្តែវិធាននេះ នឹងមិនត្រូវយកមកអនុវត្តទេ បើនីតិវិធីនៃការដោះស្រាយបន្តយូរហួសហេតុ ។

(ខ) គណៈកម្មាធិការ ត្រូវបញ្ជូនការផ្តល់យោបល់ និងអនុសាសន៍ បើសិនជាមាន ទៅជូនរដ្ឋភាគីពាក់ព័ន្ធ និងអ្នកប្តឹងទាមទារ ។

៨. គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួន នូវសេចក្តីសង្ខេបនៃបណ្តឹង និងបើសមស្រប សង្ខេបការពន្យល់ និងសេចក្តីថ្លែងការណ៍របស់រដ្ឋភាគីពាក់ព័ន្ធ ព្រមទាំងសង្ខេបការផ្តល់យោបល់ និងអនុសាសន៍របស់គណៈកម្មាធិការ ។

៩. គណៈកម្មាធិការ មានសមត្ថកិច្ចបំពេញមុខងារដែលបានចែងក្នុងមាត្រានេះបាន លុះត្រាតែយ៉ាងតិចបំផុត រដ្ឋភាគីចំនួន១០នៃអនុសញ្ញានេះ ជាប់កាតព្វកិច្ចដោយសេចក្តីប្រកាស ដែលធ្វើឡើងស្របតាមកថាខណ្ឌ១ នៃមាត្រានេះ ។

## មាត្រា ១៥

១. ក្នុងពេលរង់ចាំការសម្រេចបាននូវគោលបំណងនៃសេចក្ដីប្រកាសស្ដីពីការផ្ដល់ឯករាជ្យដល់ប្រទេស និងប្រជាជាតិអាណានិគម ដែលកំណត់នៅក្នុងសេចក្ដីសម្រេចរបស់មហាសន្និបាតលេខ១៥១៤(XV) ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៦០ បទបញ្ញត្តិនានានៃអនុសញ្ញានេះ នឹងមិនដាក់កម្រិតព្រំដែនដោយប្រការណាមួយ លើសិទ្ធិប្ដឹងទាមទារ ដែលផ្ដល់ដល់ប្រជាជាតិទាំងនេះ ដោយលិខិតុបករណ៍អន្តរជាតិផ្សេងៗ ឬដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានា នៃអង្គការសហប្រជាជាតិឡើយ ។

២. (ក) គណៈកម្មាធិការដែលបានបង្កើតស្របតាមកថាខណ្ឌ១ នៃមាត្រា៨ នៃអនុសញ្ញានេះ ត្រូវទទួលច្បាប់ចម្លងនៃបណ្ដឹងទាមទារ និងដាក់បង្ហាញមតិ និងអនុសាសន៍ស្ដីពីបណ្ដឹងទាមទារទាំងនេះ ទៅស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ដែលទទួលបន្ទុកដោះស្រាយដោយផ្ទាល់នូវបញ្ហាពាក់ព័ន្ធនឹងគោលការណ៍ និងគោលបំណងនៃអនុសញ្ញានេះ ដើម្បីពិនិត្យបណ្ដឹងទាមទាររបស់ប្រជាពលរដ្ឋ នៃដែនដីស្ថិតក្រោមអាណាព្យាបាល ដែនដីគ្មានស្វ័យភាពគ្រប់គ្រង និងដែនដីផ្សេងទៀតទាំងអស់ដែលកំណត់ឱ្យអនុវត្តតាមសេចក្ដីសម្រេចរបស់មហាសន្និបាតលេខ១៥១៤(XV) ទាក់ទងនឹងបញ្ហាដែលបានចែងក្នុងអនុសញ្ញានេះ និងដែលស្ថិតនៅចំពោះមុខស្ថាប័នទាំងនេះ។

(ខ) គណៈកម្មាធិការ ត្រូវទទួលពីស្ថាប័នមានសមត្ថកិច្ចរបស់អង្គការសហប្រជាជាតិ នូវច្បាប់ចម្លងនៃរបាយការណ៍ ស្ដីពីវិធានការខាងនីតិបញ្ញត្តិ តុលាការ រដ្ឋបាល ឬវិធានការផ្សេងទៀតដែលពាក់ព័ន្ធផ្ទាល់នឹងគោលការណ៍ និងគោលបំណងនៃអនុសញ្ញានេះ ដែលត្រូវបានអនុវត្តដោយអាជ្ញាធរគ្រប់គ្រងលើដែនដីដែលមានចែងក្នុងអនុកថាខណ្ឌ (ក) នៃកថាខណ្ឌនេះ និងត្រូវបង្ហាញមតិ និងផ្ដល់អនុសាសន៍ដល់ស្ថាប័នទាំងនេះ ។

៣. គណៈកម្មាធិការ ត្រូវបញ្ចូលទៅក្នុងរបាយការណ៍របស់ខ្លួន ជូនមហាសន្និបាត នូវសេចក្តីសង្ខេបនៃបណ្តឹងទាមទារ និងរបាយការណ៍ដែលខ្លួនបានទទួលពីស្ថាប័ននានារបស់អង្គការសហប្រជាជាតិ ព្រមទាំងការបង្ហាញមតិ និងអនុសាសន៍នៃគណៈកម្មាធិការទាក់ទងនឹងបណ្តឹងទាមទារ និងរបាយការណ៍ដែលលើកឡើងខាងលើ។

៤. គណៈកម្មាធិការត្រូវសុំអគ្គលេខាធិការអង្គការសហប្រជាជាតិឱ្យផ្តល់មកឱ្យខ្លួននូវព័ត៌មានទាំងអស់ដែលទាក់ទងនឹងគោលបំណងនៃអនុសញ្ញានេះ និងព័ត៌មានដែលអគ្គលេខាធិការអាចមានស្តីពីដែនដីដែលមានចែងក្នុងកថាខណ្ឌ២ (ក) នៃមាត្រានេះ ។

## មាត្រា ១៦

បទបញ្ញត្តិទាំងឡាយនៃអនុសញ្ញានេះ ស្តីពីវិធានសម្រាប់ការដោះស្រាយទំនាស់ ឬបណ្តឹង ត្រូវអនុវត្តដោយមិនធ្វើឱ្យប៉ះពាល់ដល់នីតិវិធីផ្សេងទៀតសម្រាប់ដោះស្រាយទំនាស់ ឬបណ្តឹងក្នុងវិស័យនៃការរើសអើងដែលមានបញ្ញត្តិក្នុងលិខិតុបករណ៍មូលដ្ឋាន ឬអនុសញ្ញានានាដែលអនុម័តដោយអង្គការសហប្រជាជាតិ និងស្ថាប័នឯកទេសនានានៃអង្គការសហប្រជាជាតិ និងមិនត្រូវរារាំងរដ្ឋភាគីក្នុងការប្រើនីតិវិធីផ្សេងដើម្បីដោះស្រាយទំនាស់ណាមួយ ស្របតាមកិច្ចព្រមព្រៀងអន្តរជាតិ មានលក្ខណៈទូទៅ ឬមានលក្ខណៈពិសេស ដែលមានជាធរមានរវាងរដ្ឋទាំងនោះឡើយ ។

## ផ្នែកទី ៣

## មាត្រា ១៧

១. អនុសញ្ញានេះ ត្រូវបើកចំហឱ្យចុះហត្ថលេខា សម្រាប់រដ្ឋសមាជិកសហប្រជាជាតិ ឬសមាជិកនៃស្ថាប័នឯកទេសណាមួយ ឬជាភាគីនៃលក្ខន្តិកៈរបស់តុលាការយុត្តិធម៌អន្តរជាតិ ឬជារដ្ឋផ្សេងទៀតដែលត្រូវបានអញ្ជើញដោយមហាសន្និបាតអង្គការសហប្រជាជាតិ ឱ្យក្លាយជាភាគីនៃអនុសញ្ញានេះ ។

២. អនុសញ្ញានេះជាកម្មវត្ថុនៃការឱ្យសច្ចាប័ន ។ លិខិតុបករណ៍ឱ្យសច្ចាប័នត្រូវតំកល់ទុកនៅនឹងអគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ។

## មាត្រា ១៨

១. អនុសញ្ញានេះត្រូវបើកចំហឱ្យរដ្ឋណាមួយ ដូចមានយោងក្នុងមាត្រា១៧ កថាខណ្ឌ១ នៃអនុសញ្ញានេះ ចូលជាសមាជិក ។

២. ការចូលជាសមាជិកត្រូវធ្វើឡើងដោយការតំកល់លិខិតុបករណ៍សុំចូលជាសមាជិកនៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៩

១. អនុសញ្ញានេះ ចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទនៃការដំកល់លិខិតុបករណ៍ទី២៧ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិក នៅនឹងអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. រដ្ឋណាដែលបានផ្តល់សច្ចាប័ន ឬចូលជាសមាជិកនៃអនុសញ្ញានេះ បន្ទាប់ពីការដំកល់លិខិតុបករណ៍ទី២៧ នៃការឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិកអនុសញ្ញានេះ នឹងត្រូវចូលជាធរមាននៅថ្ងៃទី៣០ បន្ទាប់ពីកាលបរិច្ឆេទដែលរដ្ឋនេះ ដំកល់លិខិតុបករណ៍ឱ្យសច្ចាប័ន ឬការសុំចូលជាសមាជិករបស់ខ្លួន ។

## មាត្រា ២០

១. អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវទទួល និងជូនដំណឹងទៅរដ្ឋទាំងអស់ដែលជាភាគី ឬអាចនឹងក្លាយជាភាគីនៃអនុសញ្ញានេះនូវល័ក្ខខ័ណ្ឌទាំងឡាយដែលរដ្ឋបានដាក់នៅពេលឱ្យសច្ចាប័ន ឬសុំចូលជាសមាជិក ។ រដ្ឋណាដែលជំទាស់នឹងល័ក្ខខ័ណ្ឌណាមួយ ត្រូវជូនដំណឹងទៅអគ្គលេខាធិការ ក្នុងរយៈពេល៩០ថ្ងៃ ចាប់ពីកាលបរិច្ឆេទនៃការឆ្លើយឆ្លងខាងលើ ថាខ្លួនមិនទទួលយកល័ក្ខខ័ណ្ឌនោះទេ ។

២. លិខិតុបករណ៍ដែលវិសមិតភាពនឹងកម្មវត្ថុ និងគោលបំណងនៃអនុសញ្ញានេះ មិនត្រូវបានអនុញ្ញាតទេ ហើយក៏មិនត្រូវអនុញ្ញាតដែរ នូវលិខិតុបករណ៍ណាដែលមានអានុភាពបង្អាក់ដំណើរនៃអង្គការណាមួយ ដែលបង្កើតឡើងដោយអនុសញ្ញានេះ ។ លិខិតុបករណ៍ត្រូវចាត់ថាមានវិសមិតភាព និងបន្ទុចបង្អាក់ បើ២ភាគ៣យ៉ាងតិច នៃរដ្ឋភាគីនៃអនុសញ្ញានេះ លើកការជំទាស់ ។

៣. លិខិតុបករណ៍អាចដកចេញវិញបានគ្រប់ពេល ដោយការជូនដំណឹងទៅអគ្គលេខាធិការ ។ ការជូនដំណឹងនេះ មានអានុភាពនៅកាលបរិច្ឆេទនៃការបានទទួលដំណឹង ។

## មាត្រា ២១

រដ្ឋភាគី អាចប្រកាសដកខ្លួនចេញពីអនុសញ្ញានេះ ដោយការជូនដំណឹងជាលាយលក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ។ ការប្រកាសដកខ្លួន មានអានុភាព១ឆ្នាំ បន្ទាប់ពីកាលបរិច្ឆេទដែលអគ្គលេខាធិការបានទទួលការជូនដំណឹងនេះ ។

## មាត្រា ២២

ទំនាស់រវាងរដ្ឋភាគីពីរ ឬច្រើនជាងនេះ ដែលពាក់ព័ន្ធនឹងការបកស្រាយ ឬការអនុវត្តន៍អនុសញ្ញានេះ ហើយដែលមិនអាចដោះស្រាយតាមការចរចាបាន ឬតាមនីតិវិធីដែលមានកំណត់ច្បាស់លាស់ក្នុងអនុសញ្ញានេះ ត្រូវបញ្ជូនទៅតុលាការយុត្តិធម៌អន្តរជាតិ តាមការស្នើសុំរបស់ភាគីទំនាស់ណាមួយ ដើម្បីជំនុំជំរះ លើកលែងតែរដ្ឋភាគីទំនាស់ណាមួយ សុខចិត្តទទួលយកវិធីដោះស្រាយណាមួយផ្សេងទៀត ។

## មាត្រា ២៣

១. សំណើរសុំពិនិត្យឡើងវិញនូវអនុសញ្ញានេះ អាចធ្វើទៅបានគ្រប់ពេល

ដោយរដ្ឋភាគីណាមួយ តាមការជូនដំណឹងជាលាយល័ក្ខណ៍អក្សរ ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២. មហាសន្និបាតអង្គការសហប្រជាជាតិ ត្រូវសម្រេចពីវិធានការនានាបើមាន ចំពោះការស្នើសុំនេះ ។

## មាត្រា ២៤

អគ្គលេខាធិការអង្គការសហប្រជាជាតិ ត្រូវជូនព័ត៌មានដល់រដ្ឋទាំងអស់ ស្របតាមមាត្រា១៧ កថាខណ្ឌ១ នៃអនុសញ្ញានេះ នូវចំណុចខាងក្រោម :

ក. ការចុះហត្ថលេខា ការឱ្យសច្ចាប័ន និងការចូលជាសមាជិក ស្របតាមមាត្រា១៧ និង១៨ ។

ខ. កាលបរិច្ឆេទដែលអនុសញ្ញានេះចូលជាធរមាន ស្របតាមមាត្រា១៩ ។

គ. បណ្តឹង និងសេចក្តីប្រកាសដែលទទួលបាន ស្របតាមមាត្រា១៤ មាត្រា ២០ និងមាត្រា២៣ ។

ឃ. ការប្រកាសដកខ្លួន ស្របតាមមាត្រា២១ ។

## មាត្រា ២៥

១. អនុសញ្ញានេះ ដែលមានអត្ថបទជាភាសាចិន អង់គ្លេស បារាំង រុស្ស៊ី និងអេស្ប៉ាញ៉ុល មានតម្លៃស្មើគ្នា នឹងតម្កល់ទុកនៅបណ្ណសារដ្ឋានរបស់អង្គការសហប្រជាជាតិ ។

២. អគ្គលេខាធិការអង្គការសហប្រជាជាតិត្រូវបញ្ជូនច្បាប់ចម្លងនៃអនុសញ្ញានេះ ដោយមានបញ្ជាក់ការចម្លងត្រឹមត្រូវតាមច្បាប់ដើម ទៅរដ្ឋភាគីទាំងអស់ដែលជាសមាជិក តាមប្រភេទដូចមានចែងក្នុងមាត្រា១៧ កថាខណ្ឌ១នៃអនុសញ្ញានេះ។